


# តើលោកអ្នកអាចចូលរួមតាមរបៀបណា

OFFICE OF THE
CITY CLERK
SERVING LONG BEACH SINCE 1897

ចំណុចគន្លឹះសម្រាប់រដ្ឋាភិបាលដែលទទួលបានជោគជ័យ គឺសាធារណៈជនចូលរួមដែលមានចំណង់យ៉ាងខ្លាំង។ យើងខ្ញុំចង់ឱ្យប្រជាពលរដ្ឋរស់នៅម្នាក់ៗនៅទីក្រុងឡុងប៊ិច Long Beach មានចំណេះដឹង និងមធ្យោបាយនានា ដើម្បីទទួលបានការចូលរួម។ ហើយនេះ មានវិធីមួយចំនួន ដើម្បីចាប់ផ្ដើមដំណើរការ...

1

# ចូលរួមកិច្ចប្រជុំជាសាធារណៈ ៖

មានប្រភេទកិច្ចប្រជុំជាសាធារណៈមួយចំនួន ៖

**កិច្ចប្រជុំក្រុមប្រឹក្សាក្រុង** - កិច្ចប្រជុំក្រុមប្រឹក្សាក្រុងជាទៀងទាត់ ត្រូវបានប្រារព្ធនៅ ការិយាល័យក្រុមប្រឹក្សាសាលាក្រុង នៅម៉ោង 5:00 ល្ងាច នៅថ្ងៃអង្គារ៍ជារៀងរាល់សប្ដាហ៍ ដោយមិនគិតថ្ងៃអង្គារ៍មុននៃខែនីមួយៗ។ កិច្ចប្រជុំក្រុមទាំងអស់ត្រូវបើកចំហដល់សាធារណៈជន។ ចំណុចនានាអំពីរបៀបវារៈក្រុមប្រឹក្សា អាចរាប់បញ្ចូលអ្វីៗទាំងអស់ ដូចជាសវនាការសាធារណៈ ការប្រាស្រ័យទាក់ទងពីការិយាល័យដែលបានជ្រើសរើស របាយការណ៍បុគ្គលិក និងបទបញ្ញត្តិ និងដំណោះស្រាយដែលបានស្នើឡើង។ កិច្ចប្រជុំនានា ត្រូវបានធ្វើជាអធិបតីដោយអភិបាលក្រុង ហើយចំណុចនានាអំពីរបៀបវារៈ ត្រូវបានបោះឆ្នោតដោយសមជិកក្រុមប្រឹក្សាជាប់ឆ្នោតចំនួនប្រាំបួននាក់។

**កិច្ចប្រជុំគណៈកម្មការអចិន្ត្រៃយ៍** - គណៈកម្មការអចិន្ត្រៃយ៍ទាំងអស់ ត្រូវបានបង្កើតឡើងតាមដំណោះស្រាយនៃក្រុមប្រឹក្សាក្រុង។ អភិបាលក្រុង តែងតាំងសមាជិកក្រុមប្រឹក្សានៃគណៈកម្មការអចិន្ត្រៃយ៍ និងជ្រើសរើសទុកមុនចំពោះសមាជិកណាម្នាក់ពីគណៈកម្មការនីមួយៗ ធ្វើជាប្រធានស្ដីទី និងអនុប្រធាន។ កិច្ចប្រជុំគណៈកម្មការអចិន្ត្រៃយ៍ ត្រូវបានប្រារព្ធឡើងតាមសំណើរបស់ប្រធានគណៈកម្មការ។ កិច្ចប្រជុំគណៈកម្មការអចិន្ត្រៃយ៍ បើកចំហជាសាធារណៈ លើកលែងតែការកើតមានឡើងទាំងនេះ ដែលមានកិច្ចប្រជុំបិទទ្វារ អាចត្រូវបានប្រារព្ធឡើង តាមច្បាប់ប្រោន (Brown Act) ឬច្បាប់ដែលត្រូវអនុវត្តផ្សេងៗទៀត។ ចំណុចនានានៃកិច្ចការជំនួញ ត្រូវបានកំណត់ក្នុងរបៀបវារៈ តាមការណែនាំពីប្រធានស្ដីទី អនុប្រធាន ឬសមាជិកគណៈកម្មការ។

**គណៈកម្មការ/កិច្ចប្រជុំក្រុមប្រឹក្សា** - គណៈកម្មការនានា បង្កើតឡើងពីប្រភពខុសៗគ្នាចំនួនបួន ៖ ធម្មនុញ្ញក្រុង សកម្មភាពក្រុមប្រឹក្សាក្រុង សម្លេងឆ្នោតគាំទ្រពីប្រជាពលរដ្ឋ និងសេចក្ដីបង្គាប់ឬបញ្ជាពីរដ្ឋ។

# របៀបចូលរួមកិច្ចប្រជុំជាសាធារណៈ ៖

### ការពិនិត្យឡើងវិញអំពីរបៀបវារៈ

បើលោកអ្នកនឹងចូលរួមដោយផ្ទាល់ ត្រូវប្រាកដថា ការពិនិត្យឡើងវិញអំពីរបៀបវារៈដែលត្រៀមទុកជាមុន។

### ចំណុចនានានៃរបៀបវារៈ

រងចាំសន្ទនារហូតដល់បញ្ហានោះកើតមានឡើង ហើយលោកអ្នកត្រូវបានជម្រុញលើកទឹកចិត្ត។

### តើអាចចូលរួម?

បំពេញតាម "eComment" ៖

eComment ដែលអាចប្រព្រឹត្តទៅបានតាមវែបសាយទីក្រុងឡុងប៊ិច Long Beach ហើយអាចទាក់ទងដោយផ្ទាល់ទៅចំណុចរបៀបវារៈក្រុមប្រឹក្សាក្រុង ឬអាចជា "ការសម្តែងមតិជាសាធារណៈ"។

### ការសម្តែងមតិសាធារណៈ

ឱកាសដើម្បីដោះស្រាយក្រុមប្រឹក្សាក្រុងអំពីបញ្ហាកិច្ចការជំនួញសាធារណៈដែលមិនបានរៀបរាប់នៅក្នុងរបៀបវារៈ។ បំពេញប័ណ្ណអ្នកនាំពាក្យរយៈពេល 15 នាទី មុនកិច្ចប្រជុំ។ ប័ណ្ណអ្នកនាំពាក្យ មានកំណត់សម្រាប់អ្នកនាំពាក្យចំនួន 10 នាក់ ដែលបានបញ្ជូនឈ្មោះពួកគេជាលាយលក្ខណ៍អក្សរជូនទៅស្មៀនក្រុង។ អ្នកនាំពាក្យទាំងអស់ អាចរង់ចាំរហូតដល់ការបញ្ចប់កិច្ចប្រជុំ ដើម្បីមានប្រសាសន៍។

## ហេតុអ្វីត្រូវចូលរួមកិច្ចប្រជុំជាសាធារណៈ?

មានមូលហេតុជាច្រើន ដើម្បីចូលរួមកិច្ចប្រជុំទីក្រុងជាសាធារណៈ។លោកអ្នកអាចមានបំណងគ្រាន់តែចូលរួម និងយល់ដឹងអំពីដែលកំពុងកើតមានឡើងនៅទីក្រុងនេះ។ឬលោកអ្នកអាចមានបំណងដាក់ពាក្យបណ្តឹងតវ៉ា ឬនិយាយគាំទ្រ/ផ្សព្វផ្សាយហេតុផល ឬគំនិតផ្តួចផ្តើម។ លោកអ្នកអាចអនុវត្តចំណុចទាំងនេះតាមរយៈការសន្ទនា ឬការប្រគល់ជូនអ្វីមួយទៅក្រុមប្រឹក្សា។

ចំណុចគន្លឹះសម្រាប់រដ្ឋាភិបាលដែលទទួលបានជោគជ័យ គឺសាធារណៈជនចូលរួមដែលមានចំណាប់អារម្មណ៍យ៉ាងខ្លាំង។ យើងខ្ញុំចង់ឱ្យប្រជាពលរដ្ឋរស់នៅម្នាក់ៗនៅទីក្រុងឡុងប៊ិច Long Beach មានចំណេះដឹង និងមធ្យោបាយនានា ដើម្បីទទួលបានការចូលរួម។ ហើយនេះ មានវិធីមួយចំនួន ដើម្បីទទួលបានការចូលរួម។

## 2 ទទួលដំណឹង

របៀបទទួលដំណឹង និងធ្វើបច្ចុប្បន្នភាពអំពីទីក្រុងឡុងប៊ិច Long Beach យ៉ាងដូចម្តេច ៖

- ចូលរួមប្រជុំក្រុមប្រឹក្សាក្រុង
- ទទួលបានជាប្រចាំនូវ LinkLB - LinkLB ដែលជាតំណភ្ជាប់របស់អ្នកជាមួយទីក្រុងឡុងប៊ិច Long Beach, លោកអ្នកអាចមានព័ត៌មានដែលបានផ្ញើជូនលោកអ្នកដោយផ្ទាល់ នៅពេលទីក្រុងបោះពុម្ពផ្សាយដំណឹង។
- មើលទូរទស្សន៍ផ្សាយផ្ទាល់ LBTV Live ឬមើលតាមបណ្តាញអេឡិកត្រូនិកកិច្ចប្រជុំក្រុមប្រឹក្សា។

## 3 ក្លាយជាសមាជិក

ក្រុមប្រឹក្សា ឬគណៈកម្មការមូលដ្ឋាន។

ដាក់ពាក្យសុំតាមបណ្តាញអេឡិកត្រូនិក តាមវែបសាយទីក្រុងឡុងប៊ិច Long Beach ដើម្បីក្លាយជាសមាជិកគណៈកម្មការមូលដ្ឋាន។

**WWW.LONGBEACH.GOV/CITYCLERK**

### វិធីបន្ថែម ដើម្បីចូលរួមក្នុងដំណើរការនីតិបញ្ញត្តិនៃទីក្រុង ៖

វិធីផ្សេងៗទៀតសម្រាប់ពលរដ្ឋនានា ដើម្បីចូលរួមក្នុងរដ្ឋាភិបាលមូលដ្ឋាន រួមមានការទាក់ទងសមាជិកក្រុមប្រឹក្សារបស់អ្នក ការចូលរួមក្នុងអង្គការនៅតំបន់ជិតខាង, ការដាក់បណ្តឹងទាមទារ និង ការសរសេរលិខិត។

OFFICE OF THE CITY CLERK • CITY HALL • LOBBY LEVEL • 333 W. OCEAN BLVD • LONG BEACH, CA 90802 • ទូរស័ព្ទលេខ 562 570 6101
LONGBEACH.GOV/CITYCLERK • CITYCLERK@LONGBEACH.GOV